# មជ្ឈមណ្ឌលពិនិត្យគុណភាពទឹកពិសា

## នីតិវិធីសម្អាតនិងសម្លាប់មេរោគ
## សម្រាប់ក្រោយពេលការណែនាំអំពីទឹកដាំពុះត្រូវបានបញ្ចប់សម្រាប់គ្រឹះស្ថានចំណីអាហារ

**នៅពេលក្រសួងសុខាភិបាលរដ្ឋ Rhode Island (RIDOH) បញ្ចប់ការណែនាំអំពីទឹកដាំពុះ គ្រឹះស្ថានចំណីអាហារត្រូវតែអនុវត្តតាមវិធានការដូចខាងក្រោមនេះ។**

**<u>ម៉ាស៊ីនទឹកកក</u>**

ម៉ាស៊ីនទឹកកកត្រូវតែបានលាងសម្អាតនិងសម្លាប់មេរោគដោយប្រើទឹកថ្នាំសម្អាតមួយស្លាបព្រាកាហ្វេក្នុងទឹកចំណុះមួយហ្គាឡុង មុនពេលប្រើប្រាស់។ អនុវត្តតាមនីតិវិធីសម្លាប់មេរោគដែលបានណែនាំដោយក្រុមហ៊ុនផលិត នៅក្នុងកូនសៀវភៅណែនាំសម្រាប់អ្នកប្រើប្រាស់។ យ៉ាងហោចណាស់ គ្រឹះស្ថានចំណីអាហារត្រូវតែៈ

- ដំណើរការម៉ាស៊ីនទឹកកកក្នុងរយៈពេល 24ម៉ោង និងបោះចោលទឹកកកដែលបានផលិតនៅអំឡុងពេល 24 ម៉ោងនោះ។
- លាងនិងសម្លាប់មេរោគទឹកន្លែងនៅជុំវិញនិងនៅក្នុងធុងដាក់ទឹកកក។

រាល់ឧបករណ៍ចម្រោះនៅខាងក្រៅទាំងអស់ដែលពាក់ព័ន្ធនឹងម៉ាស៊ីនទឹកកក ត្រូវតែបានសម្លាប់មេរោគ។ ត្រូវតែផ្លាស់ប្តូរបណ្តុលចម្រោះទឹកផងដែរ។

**<u>ជុំប្រព្រឹត្តកម្មទឹក</u>**

ផ្លាស់ប្តូររាល់បណ្តុលចម្រោះប្រព្រឹត្តកម្មទឹក

**<u>ម៉ាស៊ីនទឹកក្រូច</u>**

អនុវត្តតាមនីតិវិធីសម្លាប់មេរោគដែលបានណែនាំរបស់ក្រុមហ៊ុនផលិត នៅក្នុងកូនសៀវភៅណែនាំសម្រាប់អ្នកប្រើប្រាស់ ឬទាក់ទងទៅកាន់ក្រុមហ៊ុនដែលបានដំឡើងម៉ាស៊ីន(នានា) ដើម្បីធ្វើការលាងសម្អាតនិងសម្លាប់មេរោគទៅលើពួកវា។

**<u>ម៉ាស៊ីនលក់ភេសជ្ជៈស្វ័យប្រវត្តិ</u>**

ទាក់ទងទៅកាន់ក្រុមហ៊ុនដែលបានដំឡើងម៉ាស៊ីនលក់ភេសជ្ជៈស្វ័យប្រវត្តិនោះ ដើម្បីធ្វើការសម្អាតនិងសម្លាប់មេរោគឲ្យបានត្រឹមត្រូវលើម៉ាស៊ីនទាំងនោះ។ នេះអនុវត្តតែចំពោះម៉ាស៊ីនលក់ភេសជ្ជៈស្វ័យប្រវត្តិដែលបានភ្ជាប់ទៅនឹងប្រព័ន្ធទឹក ហើយត្រូវបានប្រើប្រាស់ដើម្បីផលិតរបស់ដូចជាភេសជ្ជៈត្រជាក់ៗតែប៉ុណ្ណោះ។

**<u>ស្ព្រាយ៍បាញ់បន្លែនិងត្រី</u>**

ដុំស្ព្រាយ៍ដែលមានស្រាប់ និងដុំដែលបាញ់ទឹកតាមកាលកំណត់ទៅលើផលិតផលនានាដើម្បីរក្សាភាពស្រស់បានយូរ ត្រូវតែលាងសម្អាតនិងសម្លាប់មេរោគមុនពេលប្រើប្រាស់។ 50 ទៅ 100 ចំណែកក្នុងមួយលាន (ppm) នៃសារធាតុក្លរ ឬទឹកសម្លាប់មេរោគដែលបានអនុម័តផ្សេងទៀត គួរតែត្រូវបានបាញ់ទឹកបង្ហូរតាមទុយយោក្នុងរយៈពេលយ៉ាងតិច 60វិនាទី។

**<u>ទឹកន្លែងមានទឹកពិសា</u>**

ធុងទឹកត្រជាក់ទាំងអស់ ត្រូវតែបានបាញ់ទឹកសម្អាតឲ្យបានសព្វល្អ មុនពេលប្រើប្រាស់។ ដំណើរការទឹកន្លែងមានទឹកពិសា ក្នុងពេលយ៉ាងតិច 10នាទីដើម្បីបាញ់ទឹកបង្ហូរតាមទុយយោឲ្យបានសព្វល្អ។

**ក្បាលបិទបើក/ក្បាលរ៉ូប៊ីណេ**

ក្បាលមូលបិតបើក ឬក្បាលរ៉ូប៊ីណេ ត្រូវតែបើកដំណើរការក្នុងរយៈពេល 10នាទីដើម្បីធានាថាភាពកខ្វក់ដែលអាចមាន ត្រូវបានកម្ចាត់។

**ទូរសព្ទទៅកាន់ខ្សែទូរសព្ទចម្បងរបស់មជ្ឈមណ្ឌលពិនិត្យគុណភាពទឹកពិសា តាមរយៈលេខ 401-222- 6867 ចន្ទ – សុក្រ ម៉ោង 8:30 ព្រឹក – 4 ល្ងាច ប្រសិនបើអ្នកមានសំណួរ។ ក្រៅម៉ោងធ្វើការនិងនៅថ្ងៃចុងសប្តាហ៍ សូមទូរព្ទទៅខ្សែទូរសព្ទផ្ទេសង្គ្រោះបន្ទាន់របស់ RIDOH តាមរយៈលេខ 401-276-8046។**

*បានកែប្រែនៅខែមករា ឆ្នាំ2020*